# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៩៨៥ សហវ.ករ

រាជធានីភ្នំពេញ ថ្ងៃទី១៧ខែកញ្ញា ឆ្នាំ ២០០២

# ប្រកាស
## ស្តីពី
## ការរៀបចំ និងប្រព្រឹត្តិទៅ នៃមណ្ឌលហ្វឹកហ្វឺនគយ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨.៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១២៩៨.៨៨ ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងឥស្សរជនជាអនុរដ្ឋលេខាធិការ នៃក្រសួងនិងរដ្ឋលេខាធិការដ្ឋាន នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦ /១៨ ចុះថ្ងៃទី ២៤ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១២៩៨/៩៩ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ . បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១:** បង្កើតមណ្ឌលហ្វឹកហ្វឺនគយមួយ ស្ថិតក្នុងការិយាល័យរដ្ឋបាល- បុគ្គលិក នៃទីចាត់ការគយនិងរដ្ឋាករ នឹងត្រូវបានដឹកនាំផ្ទាល់ ដោយប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ ។

**ប្រការ ២** តួនាទី ភារកិច្ច នៃ មណ្ឌលហ្វឹកហ្វឺនគយមាន ÷

- សិក្សា និង វាយតម្លៃតម្រូវការ សំរាប់កសាងសមត្ថភាព ធនធានមនុស្ស និង បង្កើនន្ទូវគុណភាពវិជ្ជាជីវៈ បច្ចេកទេស ជំនាញគយនិងរដ្ឋាករ ។
- ជ្រើសរើស និង វាយតម្លៃសមត្ថភាពមន្ត្រីរាជការគយនិងរដ្ឋាករ ដើម្បីបណ្តុះបណ្តាលនៅក្នុង-និងក្រៅប្រទេស ។
- អនុវត្តការបណ្តុះបណ្តាលរយៈពេលខ្លី មធ្យម និងវែង ដោយសហការជាមួយក្រសួង ស្ថាប័ន អង្គការជាតិ និងអន្តរជាតិ ពិសេសជាមួយវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

- ប្រមូលចងក្រង បកប្រែ បោះពុម្ពផ្សាយ និងតម្កល់ឯកសារសិក្សា ស្រាវជ្រាវ ដែលពាក់ព័ន្ធការងារជំនាញ បច្ចេកទេសគយនិងរដ្ឋាករ ។

**ប្រការ ៣** មណ្ឌលហ្វឹកហ្វឺនគយ មានក្រុមប្រឹក្សាភិបាលមួយ ដែលមានភារកិច្ច ពិនិត្យ ផ្តល់ការណែនាំ លើមាតិកាដំណើរការងារ កម្មវិធីសិក្សា ការស្រាវជ្រាវ និងពិនិត្យសកម្មភាពដទៃទៀតរបស់មណ្ឌល ។

ការតែងតាំងនិងកំណត់ភារកិច្ចរបស់ក្រុមប្រឹក្សាភិបាលនឹងត្រូវធ្វើឡើងដោយសេចក្តីសំរេចរបស់ទីចាត់ការគយនិងរដ្ឋាករ ។

**ប្រការ ៤:** ការងារប្រចាំថ្ងៃ របស់មណ្ឌលហ្វឹកហ្វឺនគយ ដឹកនាំដោយនាយករងទីចាត់ការគយនិងរដ្ឋាករមួយរូប ប្រធានការិយាល័យមួយចំនួន ជាជំនួយការតាមការងារចាំបាច់ និង ប្រធានការិយាល័យរដ្ឋបាល- បុគ្គលិក ជា ជំនួយការអចិន្ត្រៃយ៍។

**ប្រការ ៥:** មណ្ឌលហ្វឹកហ្វឺនគយ មាន ៥ ផ្នែក :

១- ផ្នែកផែនការ និង អភិវឌ្ឍន៍កម្មវិធីសិក្សា
២- ផ្នែក រដ្ឋបាល និង ហិរញ្ញវត្ថុ
៣- ផ្នែក ស្រាវជ្រាវសិក្សាប់អនុវត្ត
៤- ផ្នែក កុំព្យូទ័រ
៥- បណ្ណាល័យ

**ប្រការ ៦:** ក្រុមប្រឹក្សាភិបាលមានសិទ្ធិទំនាក់ទំនងស្នើសុំ ទីប្រឹក្សា ឬ អ្នកជំនាញការ ព្រមទាំងការឧបត្ថម្ភមធ្យោបាយផ្សេងៗតាមការចាំបាច់ ដើម្បីប្រើប្រាស់ក្នុងទិសដៅអភិវឌ្ឍន៍សកម្មភាពរួមរបស់មណ្ឌល ។

**ប្រការ ៧** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា នាយកទីចាត់ការគយនិងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ និង ប្រធាននាយកដ្ឋានបុគ្គលិក ត្រូវទទួលអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
  « ជូនជ្រាប »
- ដូចប្រការ ៧ « ដើម្បីអនុវត្ត »
- ឯកសារ - កាលប្បវត្តិ

គាត ឈន់